

# នៅជាប់

## អំណាច
## និងភាពស្រស់ស្អាតនៃព្រះបន្ទូលរបស់ព្រះ

© 2021 by Every Nation Churches & Ministries. All rights reserved.

Scripture quotations, unless otherwise noted, are from The Holy Bible,
English Standard Version (ESV) Copyright 2001 by Crossway,
a publishing ministry of Good News Publishers.

EveryNation.org/Fasting #ENfast2021

# មាតិកា


ការរៀបចំខ្លួនដើម្បីតមអាហារ ..................................................... 2

គម្រោងតមរបស់ខ្ញុំ........................................................................ 5

សេចក្តីផ្តើម:  ព្រះបន្ទូលគឺដូចជានំប៉័ង......................................... 13

ថ្ងៃទី១: ព្រះបន្ទូលគឺជាគ្រាប់ពូជ .................................................... 17

ថ្ងៃទី២: ព្រះបន្ទូលគឺជាពន្លឺ ........................................................... 20

ថ្ងៃទី៣: ព្រះបន្ទូលគឺជាកញ្ចក់...................................................... 24

ថ្ងៃទី៤: ព្រះបន្ទូលគឺជាញញួរ ...................................................... 28

ថ្ងៃទី៥: ព្រះបន្ទូលគឺជាដាវ ........................................................... 31

ជារួមមក: ព្រះបន្ទូលគឺជាគ្រឹះដ៏រឹងមាំរបស់យើង.......................... 35

# ការរៀបចំខ្លួនដើម្បីតមអាហារ

**ហេតុអ្វីតមអាហារ**?

ការតមអាហារ គឺជាឧបករណ៍ខាងវិញ្ញាណដែលព្រះជាម្ចាស់ប្រើប្រាស់ដើម្បីជម្រុញព្រះរាជ្យរបស់ព្រះអង្គ ផ្លាស់ប្តូរវាសនារបស់ប្រជាជាតិនានា ជំរុញឲ្យមានការផុសផុលខាងវិញ្ញាណ និងនាំយកជ័យជំនះដាក់ក្នុងជីវិតមនុស្សទាំងអស់។ ក្រុមជំនុំគ្រប់ជាតិសាសន៍ និងព័ន្ធកិច្ចតាមសាលា ធ្វើការអធិស្ឋាននេះចាប់ផ្តើមរៀងរាល់ដើមឆ្នាំថ្មី ដោយមានរយៈពេល៥ថ្ងៃនៃការអធិស្ឋាននិងតមអាហារ ដើម្បីបន្ទាបខ្លួនរបស់យើងចំពោះព្រះជាម្ចាស់, ថ្វាយខ្លួនយើងទៅកាន់ព្រះជាម្ចាស់សម្រាប់ឆ្នាំខាងមុខនេះ ហើយសហការគ្នាដើម្បីទទួលបានភាពទម្លុះទម្លាយ។

**ព្រះយេស៊ូបានតមអាហារ**!

*ពេលនោះ ព្រះវិញ្ញាណនាំព្រះយេស៊ូទៅវាលរហោស្ថាន អោយមារសាតាំងល្បួង បន្ទាប់ពីបានតមអាហារអស់រយៈពេលសែសិបថ្ងៃ សែសិបយប់មក ព្រះអង្គក៏ឃ្លាន។ (ម៉ាថាយ៤:១-២)*

*ព្រះយេស៊ូយាងត្រលប់ទៅស្រុកកាលីឡេវិញ ប្រកបដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ព្រះនាមរបស់ព្រះអង្គលឺល្បីល្បាញពាសពេញតំបន់នោះ។ (លូកា ៤:១៤)*

ព្រះយេស៊ូជ្រាបថា ព្រះអង្គត្រូវការកម្លាំងខាងវិញ្ញាណ ដើម្បីអាចបំពេញតាមព្រះហឫទ័យរបស់ព្រះបិតាបាន។ ការតមអាហារធ្វើឲ្យយើងខ្លាំងខាងឯវិញ្ញាណ និងធ្វើឲ្យយើងត្រៀមខ្លួនបានរួចជាស្រេចក្នុងការបំពេញភារកិច្ចដែលព្រះជាម្ចាស់ប្រទានឲ្យយើងធ្វើ។

**ការតមអាហារគឺជាសកម្មភាពបន្ទាបខ្លួន និងញែកខ្លួនឲ្យបានវិសុទ្ធ**

*នៅក្បែរព្រែកអាហាវ៉ានោះ ខ្ញុំបានប្រកាស់អោយធ្វើពិធីតមអាហារ ដើម្បីដាក់ខ្លួននៅចំពោះព្រះភ័ក្ត្រនៃព្រះរបស់យើង សូមព្រះអង្គប្រទានអោយយើង និងកូនចៅរបស់យើង ធ្វើដំណើរប្រកបដោយសុខសាន្ត ហើយអោយទ្រព្យសម្បត្តិរបស់យើងបានគង់វង្សផង (អែសរ៉ា ៨:២១)*

---

ការបន្ទាបខ្លួនតាមរយៈការតមអាហារ និងអធិស្ឋានធ្វើអោយយើងទទួលបាននូវព្រះគុណរបស់ព្រះជាម្ចាស់ និងមានផ្លូវចូលទៅកាន់ដួងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

**ការតមអាហារធ្វើឲ្យយើងបានស្និទ្ធស្នាល និងងាយស្តាប់លឺព្រះសូរសៀងព្រះជាម្ចាស់**

*នៅពេលដែលអ្នកទាំងនោះកំពុងតែធ្វើពិធីថ្វាយបង្គំព្រះអម្ចាស់ និងតមអាហារ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា៖ «ចូរញែកបារណាបាស និងសូលចេញដោយឡែក ដ្បិតយើងបានហៅអ្នកទាំងពីរមក អោយបំពេញកិច្ចការដែលយើងនឹងដាក់អោយធ្វើ»។ (**កិច្ចការ១៣:២**)*

ពេលយើងច្រានចោលការស្រេកឃ្លាន និងភាពរំខានពីលោកិយ៍ យើងអាចស្ដាប់លឺព្រះសូរសៀងរបស់ព្រះជាម្ចាស់បានច្បាស់ជាងមុន។ យើងនឹងអាចផ្តោតទៅលើទ្រង់ និងចុះចូលទៅនឹងផែនការរបស់ទ្រង់ បានទាំងស្រុង។

---

## ការតមអាហារនាំអោយមានការផ្លាស់ប្រែជាថ្មី និងរួសរាននឡើងវិញ

*ប្រសិនបើប្រជារាស្ត្ររបស់យើង គឺប្រជារាស្ត្រដែលជាកម្មសិទ្ធរបស់យើងផ្ទាល់ នាំគ្នាបន្ទាបខ្លួនអធិស្ឋាន និងស្វែងរកយើង ហើយប្រសិនបើគេបោះបង់ផ្លូវអាក្រក់របស់ខ្លួន យើងនឹងស្ដាប់គេពីស្ថានបរមសុខ យើងនឹងលើកលែងទោសអោយគេរួចពីបាប ព្រមទាំងប្រោសស្រុកគេអោយបានជាផង (**២របាក្សត្រ៧:១៤**)*

ក្នុងប្រវត្តិសាស្ត្រ យើងឃើញថាព្រះជាម្ចាស់តែងតែឆ្លើយតបនឹងសំណូមអធិស្ឋាន និងការតមអាហារ ដោយព្រះអង្គរំដោះគេចេញពីគ្រោះមហន្តរាយ និងអោយប្រជាជាតិរបស់គេរស់រានឡើងវិញ។ ការតមអាហារជំរុញឲ្យយើងអធិស្ឋាន និងទូលអង្វរព្រះជាម្ចាស់សំរាប់អ្នកឯទៀតៗបានប្រសើរជាងមុន។

## ការតមអាហារធ្វើអោយមានសុខភាពល្អ

ការតមអាហារជួយសម្អាតប្រព័ន្ធរំលាយអាហាររបស់យើង។ វេជ្ជបណ្ឌិតបានអះអាងថា ការតមអាហារជួយព្យាបាលជំងឺមួយចំនួនបាន។ ការតមអាហារក៏ជួយឲ្យយើងអាចយកឈ្នះលើទំលាប់អាក្រក់មួយចំនួនផងដែរ។

## ការរៀបចំខ្លួនមុនពេលតមអាហារ

*បន្ទាប់មកលោកយ៉ូស្វេមានប្រសាសន៍ទៅកាន់ប្រជាជនថា៖« ចូរញែកខ្លួនអោយវិសុទ្ធ ដ្បិតថ្ងៃស្អែកព្រះអង្គម្ចាស់នឹងសម្ដែងការអស្ចារ្យនៅកណ្ដាលចំណោមអ្នករាល់គ្នា»។ (**យ៉ូស្វេ៣:៥**)*

**អធិស្ឋាន**—ចូរចំណាយពេលអានព្រះគម្ពីរ និងអធិស្ឋានមុនពេលតមអាហារ។ សូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធជួយដឹកនាំពីអ្វីដែលត្រូវអធិស្ឋាន នៅទំព័រទី៩ដល់ទី១១។ ចូរសរសេរពីគោលដៅជំនឿ និងការអធិស្ឋានស្នើរសុំឲ្យបានជាក់លាក់សំរាប់ ក្រុមគ្រួសារ មិត្តភ័ក្រ្ត ក្រុមជំនុំ និងប្រជាជាតិរបស់លោកអ្នក។

**ប្តេជ្ញាចិត្ត**—ជ្រើសរើសប្រភេទនៃការតមអាហារ ហើយប្តេជ្ញាចិត្តធ្វើវាឲ្យបាន។ កត់ចំណាំនូវប្រភេទតមរបស់លោកអ្នកក្នុងទំព័រទី៨។ ចូរទូលសុំព្រះគុណពីព្រះអង្គ ក្នុងការធ្វើវាឲ្យបាន។

**សកម្មភាព**—កាត់បន្ថយការញ៉ាំបន្តិចម្តងៗ ១សប្តាហ៍ ឬបីថ្ងៃមុនពេលការតមអាហារមកដល់។ ជៀសវាងការញ៉ាំអាហារណាដែលមានជាតិស្ករ និងខ្លាញ់ច្រើន។ កាត់បន្ថយសកម្មភាពកម្លាំងកាយយ៉ាងហោចណាស់មួយសប្តាហ៍មុនថ្ងៃតម និងក្នុងពេលតមអាហារ។ រកដៃគូរអធិស្ឋានឲ្យគេសរសេរឈ្មោះនៅទំព័រទី៧។

**កត់ចំណាំ**: *ប្រសិនបើអ្នកមានផ្ទៃពោះ ឬត្រូវបំបៅទារក ឬលេបថ្នាំជាប្រចាំ សូមពិគ្រោះជាមួយគ្រូពេទ្យជាមុនសិនមុនសម្រេចចិត្តតម។ បើលោកអ្នកស្ថិតក្នុងស្ថានភាពណាមួយដែលមិនអាចតមទាំងស្រុងបាន ចូរជ្រើសយកជំរើសណាមួយដែលសមស្របនឹងស្ថានភាពជាក់ស្តែងរបស់លោកអ្នក។*

**កំឡុងពេលតមអាហារ**

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា មនុស្សមិនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូលដែលចេញពីព្រះឳស្ឋរបស់ព្រះជាម្ចាស់ផងដែរ។ (ម៉ាថាយ៤:៤)*

***ផ្តោត***—*ទុកពេលជាមួយព្រះ និងបំពេញកូនសៀវភៅនេះ។ ត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការគោរពតាមព្រះបន្ទូល និងការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

***អធិស្ឋាន***—*ចូលរួមការប្រជុំអធិស្ឋានរបស់ក្រុមជំនុំ។ អធិស្ឋានឲ្យគ្រួសារ សាលារៀន គ្រូគង្វាល បេសកជនផ្សាយដំណឹងល្អ និងប្រជាជាតិរបស់លោកអ្នកមួយសប្តាហ៍ពេញ។*

***បំពេញជំនួស***—*យកពេលបរិភោគអាហារទៅអានព្រះគម្ពីរ និងអធិស្ឋាន។ផឹកទឹក និងសម្រាកឲ្យបានច្រើន តាមតែអាចធ្វើទៅបាន។ ត្រូវត្រៀមខ្លួនទទួលយកផលវិបាកមួយចំនួនដូចជាភាពអស់កម្លាំង ឆាប់ឆេវឆាវ និងពិបាកទប់អារម្មណ៍ជាដើម។*

***បញ្ចប់ការតមអាហារ***

*ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្តាប់យើងជាមិនខាន។ បើយើងដឹងថាព្រះអង្គទ្រង់ព្រះសណ្តាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថាយើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។* ***១យ៉ូហាន៥:១៤-១៥***

***បរិភោគ***—*បរិភោគអាហារឡើងវិញ បន្តិចម្តងៗ។*
*ក្រពះរបស់លោកអ្នកត្រូវការពេលវេលាដើម្បីសម្របទៅនឹងអាហារប្រចាំថ្ងៃឡើងវិញ។*
*ចាប់ផ្តើមដោយការបរិភោគបន្លែ ផ្លែឈើ និងទឹកផ្លែឈើស្រស់ ហើយបរិភោគបន្តិចម្តងៗ។*

***អធិស្ឋាន***—*កុំឈប់អធិស្ឋាន! ទុកចិត្តលើភាពស្មោះត្រង់ និងពេលវេលាត្រឹមត្រូវរបស់ព្រះជាម្ចាស់។*
*បន្តភាពក្លៀវក្លាសម្រាប់ព្រះអង្គពេញមួយឆ្នាំនេះ។*
*ត្រូវមានជំនឿថាព្រះជាម្ចាស់នឹងឆ្លើយតបការអធិស្ឋានរបស់លោកអ្នក។*

# គំរោងតមរបស់ខ្ញុំ

### ថ្ងៃទី១

ជំរើសប្រភេទតម:

☐ ញាំតែទឹកប៉ុណ្ណោះ

☐ ញាំតែរបស់រាវប៉ុណ្ណោះ

☐ ទទួលទានអាហារតែមួយពេល

☐ ផ្សេងៗ_______

ការចូលរួមប្រជុំអធិស្ឋាន:

______________________

### ថ្ងៃទី២

ជំរើសប្រភេទតម:

☐ ញាំតែទឹកប៉ុណ្ណោះ

☐ ញាំតែរបស់រាវប៉ុណ្ណោះ

☐ ទទួលទានអាហារតែមួយពេល

☐ ផ្សេងៗ_______

ការចូលរួមប្រជុំអធិស្ឋាន:

______________________

### ថ្ងៃទី៣

ជំរើសប្រភេទតម:

☐ ញាំតែទឹកប៉ុណ្ណោះ

☐ ញាំតែរបស់រាវប៉ុណ្ណោះ

☐ ទទួលទានអាហារតែមួយពេល

☐ ផ្សេងៗ_______

ការចូលរួមប្រជុំអធិស្ឋាន:

______________________

### ថ្ងៃទី៤

ជំរើសប្រភេទតម:

☐ ញាំតែទឹកប៉ុណ្ណោះ

☐ ញាំតែរបស់រាវប៉ុណ្ណោះ

☐ ទទួលទានអាហារតែមួយពេល

☐ ផ្សេងៗ_______

ការចូលរួមប្រជុំអធិស្ឋាន:

______________________

### ថ្ងៃទី ៥

ជំរើសប្រភេទតម:

☐ ញាំតែទឹកប៉ុណ្ណោះ

☐ ញាំតែរបស់រាវប៉ុណ្ណោះ

☐ ទទួលទានអាហារតែមួយពេល

☐ ផ្សេងៗ_______

ការចូលរួមប្រជុំអធិស្ឋាន:

______________________

## ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់ . . .

សំណូមអធិស្ឋានដែលទទួលបានការឆ្លើយតបពីព្រះជាម្ចាស់

សរសេរចំណុចសំខាន់ៗ, សំណូមអធិស្ឋានដែលទទួលបានការឆ្លើយតបពីព្រះជាម្ចាស់,

និងបទពិសោធដែលបានឆ្លងកាត់ក្នុងឆ្នាំ២០២១

## នៅក្នុងឆ្នាំ២០២២, ខ្ញុំជឿជាក់ព្រះជាម្ចាស់សម្រាប់. . .

### គោលដៅសេចក្តីជំនឿផ្ទាល់ខ្លួន

- ការផុសផុលខាងវិញ្ញាណ• ការប្រោសឲ្យជា • ភាពចម្រុងចម្រើន និងភាពសម្បូរហូរហៀរ • ការឲ្យដោយចិត្តសប្បុរស . . .

### ក្រុមគ្រួសាររបស់ខ្ញុំ

- ការស្តារឡើងវិញនៃទំនាក់ទំនងក្នុងគ្រួសារ • សេចក្តីសង្គ្រោះដល់សមាជិកក្រុមគ្រួសារទាំងមូល . . .

### ការសិក្សា/ការងាររបស់ខ្ញុំ

- ល្អប្រសើ • តម្លើងឋានៈ . . .

### ព័ន្ធកិច្ចរបស់ខ្ញុំ

- ការលូតលាស់ក្រុមតូច • សេចក្តីសង្គ្រោះសម្រាប់មិត្តរួមការងារ និងមិត្តរួមថ្នាក់ . . .

---

*"ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ទៀតថា ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើមានពីរនាក់នៅលើផែនដីនេះ រួមចិត្តគំនិតគ្នា ទូលសូមអ្វីក៏ដោយ ព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខនឹងប្រទានអោយជាមិនខាន" **ម៉ាថាយ១៨:១៩***

**ដៃគូអធិស្ឋានរបស់ខ្ញុំ:** ______________________________________________

## ខ្ញុំប្តេជ្ញាអធិស្ឋានសម្រាប់ . . .

ឈ្មោះ សំណូមអធិស្ឋាន

## ខ្ញុំប្តេជ្ញាអធិស្ឋានសម្រាប់ . . .

### ក្រុមជំនុំរបស់ខ្ញុំ

- ថ្នាក់ដឹកនាំក្រុមជំនុំ • ការផ្គត់ផ្គង់ • ព័ន្ធកិច្ចបង្កើតសិស្សសាវ័ក . . .

### សហគមន៍របស់ខ្ញុំ

- សាលា និងវិទ្យាស្ថានអប់រំ • រដ្ឋាភិបាលក្នុងស្រុក • ឱកាសផ្សព្វផ្សាយតាមតំបន់ផ្សេងៗ . . .

### ប្រជាជាតិរបស់ខ្ញុំ

- មន្ត្រីរដ្ឋាភិបាល • ការផុសផុលខាងវិញ្ញាណ • ភាពចម្រុងចម្រើនផ្នែកសេដ្ឋកិច្ច • សន្តិភាព និងរបៀបរៀបរយ . . .

# បច្ចុប្បន្នក្រុមជំនុំគ្រប់ជាតិសាសន៍ បានធ្វើការរួចមកហើយនៅក្នុង៨១ប្រទេស

សូមបន្តអធិស្ឋានសម្រាប់ប្រទេសដែលនៅសល់ចំនួន១១៤ប្រទេស
ហើយយើងជឿថាព្រះជាម្ចាស់នឹងបើកទ្វារសម្រាប់ការដាំក្រុមជំនុំបន្ថែមទៀត

Afghanistan
Albania
Algeria
Andorra
Angola
Antigua and Barbuda
Argentina
Azerbaijan
Bahamas
Barbados
Belarus
Belize
Benin
Bosnia and Herzegovina
Bulgaria
Burkina Faso
Cabo Verde
Cameroon
Central African Republic
Chad
Comoros
Congo
Costa Rica
Côte d'Ivoire
Cuba
Cyprus
Czech Republic
Democrat Republic of the Congo
Denmark
Djibouti
Dominica
Ecuador
Egypt
El Salvador
Equatorial Guinea
Eritrea
Estonia
Ethiopia
Finland
Gambia
Greece
Grenada
Guatemala
Guinea
Guinea-Bissau
Guyana
Haiti
Hungary
Iceland
Iraq
Israel
Italy
Jamaica
Kenya
Kiribati
Latvia
Lebanon
Lesotho
Liberia
Libya
Liechtenstein
Lithuania
Luxembourg
Macedonia
Madagascar
Mali
Malta
Marshall Islands
Mauritania
Micronesia
Moldova
Monaco
Montenegro
Morocco
Nauru
Niger
North Korea
Norway
Palau
Palestine
Paraguay
Russia
Rwanda
Saint Kitts and Nevis
Saint Lucia
Saint Vincent and the Grenadines
Samoa
San Marino
Sao Tome and Principe
Senegal
Serbia
Seychelles
Slovakia
Slovenia
Solomon Islands
Somalia
South Sudan
Sudan
Suriname
Sweden
Switzerland
Syria
Tanzania
Tonga
Trinidad and Tobago
Tunisia
Turkmenistan
Tuvalu
Uruguay
Uzbekistan
Vanuatu
Vatican City
Yemen



ក្រុមជំនុំចំនួន៤៥៨ប្រទេស ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស

ក្រុមជំនុំសកម្មដែលបានដាំទាំង៨៨ប្រទេស

អធិស្ឋានសម្រាប់ការដាំក្រុមជំនុំជាច្រើនបន្ថែមទៀត

---

***បើព្រះអង្គសុំ យើងនឹងប្រគល់ប្រជាជាតិនានាអោយព្រះអង្គទុកជាមត៌កយើងក៏នឹងប្រគល់ផែនដីទាំងមូលអោយព្រះអង្គទុកជាកម្មសិទ្ធិដែរ។ ទំនុកតម្កើង២:៨***

អធិស្ឋានសម្រាប់ការដាំក្រុមជំនុំថ្មីដូចដែលពួកគេបង្កើតសិស្សសាវ័កព្រមទាំងឃើញពីសេចក្តីត្រូវការនៅក្នុងសហគមន៍របស់ពួកគេ និងចែកចាយដំណឹងល្អនៃព្រះយេស៊ូគ្រិស្តនៅក្នុងទីក្រុងថ្មីរបស់ពួកគេ។

Armenia
Australia
Botswana
Brazil
Cambodia
Canada
China
Croatia
France
Gabon
Georgia
Honduras
India
Indonesia
Iran
Kazakhstan
Laos
Malawi
Maldives
Mexico
Mongolia
Mozambique
Nepal
Netherlands
New Zealand
Nicaragua
Nigeria
Panama
Portugal
Romania
South Africa
Tajikistan
Timor-Leste
United Arab Emirates
United States
Vietnam
Zambia
Zimbabwe

## សាលាចំនួន១៩០៥ បានបង្កើតឡើង និងការធ្វើព័ន្ធកិច្ចតាមសាលា

*«. . . ហេតុនេះ ចូរអង្វរម្ចាស់ស្រែ អោយចាត់អ្នកច្រូតមកក្នុងស្រែរបស់លោក»* ម៉ាថាយ៩:៣៨

## អធិស្ឋានសម្រាប់:

- ការភ្ជាប់ទំនាក់ទំនងជាមួយសិស្សថ្មីជាមួយដំណឹងល្អនៅក្នុងឆ្នាំនេះ
- បេសកជនតាមសាលា និងសមាជិកក្រុមជំនុំទទួលបានប្រាជ្ញាក្នុងការផ្សព្វផ្សាយដំណឹងល្អ និងការបង្កើតសិស្សសាវ័កនៅតាមសកលវិទ្យាល័យ
- ការទទួលបានការអនុញ្ញាត ឬការយល់ព្រមពីសកលវិទ្យាល័យ ដើម្បីទទួលបានការផ្សារភ្ជាប់ទំនាក់ទំនងជាមួយសិស្សានុសិស្ស
- សេចក្តីសុខសាន្តសម្រាប់សិស្សានុសិស្សដែលរងផលបះពាល់ដោយសារជំងឺកូវីត១៩
- ការផ្គត់ផ្គង់សម្រាប់សិស្សានុសិស្សដែលបានរងផលប៉ះពាល់ដោយសារជំងឺកូវីត១៩
- បេសកជនតាមសាលាទទួលបានប្រាជ្ញា ដើម្បីរកវិធីសាស្ត្រល្អៗជួយដល់សិស្សានុសិស្ស

*9:38 Challenge:* កំណត់នាឡិការោទ៍ ម៉ោង៩:៣៨នាទីព្រឹក (ឬល្ងាច តាមពេលវេលាដែលសមស្របសម្រាប់លោកអ្នក)។ រាល់ពេលដែលនាឡិការោទ៍ សូមឆ្លៀតពេលបន្តិចដើម្បីអធិស្ឋានទៅកាន់ព្រះជាម្ចាស់ សូមឲ្យទ្រង់បញ្ជូនបេសកជន និងអ្នកដាំក្រុមជំនុំបន្ថែមទៀត ដែលមានភាពក្លាហានក្នុងការប្រកាសដំណឹងល្អរហូតដល់អវសានកាលនៃពិភពលោក។



# ការណែនាំ



## ព្រះបន្ទូលគឺដូចជានំប៉័ង

***អាន ទុកតិយកថា ៨: ១-២០***

"ព្រះអង្គបានឲ្យអ្នកជួបទុក្ខលំបាក និងការអត់ឃ្លាន ព្រះអង្គប្រទាននំម៉ាណាឲ្យអ្នកបរិភោគ គឺជាអាហារដែលអ្នក និងដូនតារបស់អ្នក ពុំធ្លាប់ស្គាល់។ ធ្វើដូច្នេះ ព្រះអង្គប្រៀនប្រដៅឲ្យអ្នកដឹងថា មនុស្សមិនមែនរស់ដោយអាហារប៉ុណ្ណោះទេ តែមនុស្សរស់ដោយសារព្រះបន្ទូលទាំងប៉ុន្មាន ដែលចេញមកពីព្រះឱស្ឋរបស់ព្រះអម្ចាស់។"
***ទុកតិយកថា ៨ : ៣***

អានបន្ថែម***: ម៉ាថាយ ៤: ៣-៤; លូកា ៤: ១-៤; យ៉ូហាន ៤: ៣៤***

នំប៉័ងគឺជាអាហារសំខាន់របបអាហារនៃបុព្វការីជនជិតខាងបូព៌ា។ សូម្បីតែសព្វថ្ងៃនេះវប្បធម៌ជាច្រើនមាននំប៉័ងដែលប្លែក និងពេញនិយមចំពោះរបបអាហាររបស់ពួកគេ។ នំប៉័ងដែលមានឈ្មោះថា នំបាហ្គេត ខ្រាញ់ឈឺ ( baguette crunchy ) នៅក្នុងប្រទេសបារាំង, នំរ៉ូទី ( roti unleavened ) នៅក្នុងប្រទេសឥណ្ឌា, នំអ៊ីនជ័រ៉ា ស្ពុងជី ( injera spongy ) នៅក្នុងប្រទេសអេត្យូពី, នំថតទីលឡា ( tortilla ) នៅម៉ិកស៊ិកកូ និង នំ ផានឌែសាល ( pandesal )នៅក្នុងប្រទេសហ្វីលីពីន។

ប៉ុន្តែនៅ***ទុតិទិយកថា ៨:៣*** លោកម៉ូសេប្រកាសថា មនុស្សមិនមែនរស់ដោយអាហារតែមួយមុខទេ។ កាលជនជាតិអ៊ីស្រាអែលនៅទីរហោស្ថាន ព្រះជាម្ចាស់បានប្រទានអាហារឲ្យពួកគេដូចជាភ្លៀងធ្លាក់ គឺជានំមាណា ជាអាហារ ដែលដូចជានំប៉័ងមកពីស្ថានសួគ៌។ ឥឡូវនេះ ដោយពួកគេរៀបចំខ្លួនចូលទៅក្នុងទឹកដីសន្យា ដែលជាទឹកដីដ៏បរិបូរណ៍ ម៉ូសេឆ្លៀតពេលរំលឹកប្រជាជនអំពីអ្នកដែលចិញ្ចឹមពួកគេនៅទីរហោស្ថាន។ ហើយទោះបីជាពួកគេនឹងលែងត្រូវការនំប៉័ងដែលធ្លាក់មកពីលើមេឃនៅកន្លែងថ្មីដែលពួកគេនឹងទៅក៏ដោយ ក៏ពួកគេត្រូវតែពឹងផ្អែកលើព្រះជាម្ចាស់ដដែល។ វាគឺជាការជឿទុកចិត្ត និងការគោរពតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ថាពួកគេនឹងរស់នៅ និងរីកចម្រើននៅក្នុងស្រុក។ ពួកគេត្រូវការព្រះបន្ទូលរបស់ទ្រង់

ដូចជាការត្រូវការនំប៉័ងដើម្បីរស់ដូចគ្នា។ដូចគ្នាដែរការពឹងផ្អែករបស់យើងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គួរតែដូចជាការពឹងផ្អែករបស់យើងលើនំប៉័ងដែរ។ ជារៀងរាល់ថ្ងៃនៃការតមអាហារនេះ រាងកាយរបស់យើងនឹង ចង់បានអាហារបំប៉នកាន់តែច្រើនឡើងៗ ដូចអ្វីដែលនំប៉័ងអាចផ្តល់ឱ្យ។ ប៉ុន្តែការស្រេកឃ្លានអាហារ នេះឱ្យ យើងយល់ដឹងថាតម្រូវការចាំបាច់ របស់យើងគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជានំប៉័ងសម្រាប់វិញ្ញាណរបស់យើង។ ដូចជារូបកាយរបស់យើងប្រាថ្នាចង់បាននំប៉័ង យើងគួរតែប្រាថ្នាចង់បានព្រះបន្ទូលរបស់ព្រះម្ចាស់ដូចគ្នា សម្រាប់រស់នៅដោយដឹងខ្លួនជានិច្ចអំពីតម្រូវការរបស់យើងសម្រាប់ទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ។

ជាក់ស្តែង យើងរៀននៅក្នុងសៀវភៅដំណឹងល្អរបស់យ៉ូហានថា ព្រះយេស៊ូវទ្រង់ជាព្រះបន្ទូលនៃព្រះជាម្ចាស់។ ទ្រង់ហៅខ្លួនឯងថាជា "នំប៉័ងជីវិត" ដោយសន្យាថាអ្នកណាដែលមករកគាត់នឹងមិនដែលស្រេកឃ្លានឡើយ។ ពេលយើងមកឈរចំពោះមុខទ្រង់ ហើយបំពេញខ្លួនយើងដោយព្រះបន្ទូលរបស់ព្រះអង្គ នោះយើងអាចទទួលបានសេចក្តីសង្គ្រោះពីទ្រង់យ៉ាងពិតប្រាកដ។
នៅពេលដែលយើងចូលទៅក្នុងការអធិស្ឋាន និងការតមអាហារពេញមួយសប្តាហ៍ការស្រេកឃ្លានរបស់យើងសម្រាប់នំប៉័ងកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃសូមឱ្យចំណង់សម្រាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែកើនឡើងដូចគ្នា។

សូមគិតអំពីស្ថានភាពមួយដែលអ្នកត្រូវពឹងផ្អែកលើព្រះ។ សូមអរព្រះគុណទ្រង់សម្រាប់ការទ្រទ្រង់អ្នកតាមរយៈវា។

តើខគម្ពីរ ឬអត្ថបទណាដែលបានបន្តលើកទឹកចិត្តអ្នកកាលពីឆ្នាំមុននេះ? សូមចំណាយពេលដើម្បីសរសើរតម្កើងព្រះជាម្ចាស់ ព្រោះព្រះបន្ទូលរបស់ទ្រង់គួរឱ្យទុកចិត្ត និងមានអំណាចក្នុងជីវិតរបស់អ្នក។

*ព្រះបន្ទូលរបស់ព្រះជាម្ចាស់ទ្រទ្រង់យើង។*

"ព្រះអង្គបានឲ្យអ្នកជួបទុក្ខលំបាក និងការអត់ឃ្លាន ព្រះអង្គប្រទាននំម៉ាណាឲ្យអ្នកបរិភោគ គឺជាអាហារដែលអ្នក និងដូនតារបស់អ្នកពុំធ្លាប់ស្គាល់។ ធ្វើដូច្នេះ ព្រះអង្គបង្រៀនប្រដៅឲ្យអ្នកដឹងថា មនុស្សមិនមែនរស់ដោយអាហារប៉ុណ្ណោះទេ តែមនុស្សរស់ដោយសារព្រះបន្ទូលទាំងប៉ុន្មាន ដែលចេញមកពីព្រះឱស្ឋរបស់ព្រះអម្ចាស់។"

**ទុតិយកថា ៨ : ៣**

ព្រះអង្គ អរព្រះគុណទ្រង់សម្រាប់អំណោយនៃព្រះគម្ពីរ។
តាមរយៈព្រះបន្ទូលរបស់ទ្រង់ ដែលមានព្រះបន្ទូលមកកាន់ ហើយរំលឹកថា ទ្រង់គឺសម្រាប់កូន។ ព្រះអង្គបង្ហាញពីអត្តចរិតដែលមិនប្រែប្រួលរបស់ទ្រង់ ហើយខ្ញុំរៀនស្តាប់សំឡេងរបស់ទ្រង់ ដូចដែលពេលខ្ញុំអាន និងសញ្ជឹងគិតលើព្រះគម្ពីរ។ ឱព្រះអម្ចាស់
សូមជួយទូលបង្គំឲ្យបានសម្រេចនូវចំណង់ក្នុងការគោរពចុះចូលតាមព្រះបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ ដែលជាបំណងប្រាថ្នាក្នុងការដើរជាមួយទ្រង់។ ព្រះបន្ទូលទ្រង់ចាក់បំពេញវិញ្ញាណទូលបង្គំ ហើយបំពេញចិត្តទូលបង្គំ។ ដោយកូនអធិស្ឋាន តមអាហារ ហើយញែកខ្លួន សម្រាប់ទ្រង់ក្នុងសប្តាហ៍នេះ សូមឲ្យការយល់ដឹង និងសេចក្តីស្រឡាញ់របស់កូន ចំពោះព្រះអង្គកើនឡើង នៅពេលកូនទៅជិតទ្រង់។ នៅក្នុងព្រះនាមព្រះយេស៊ូវ !

អាម៉ែន!

# ថ្ងៃទី ១

# ព្រះបន្ទូលគឺជាគ្រាប់ពូជ

*សូមអាន: ១ ពេត្រុស ១ : ១៣ - ២៥*

"ព្រះជាម្ចាស់បានប្រោសបងប្អូនឲ្យកើតជាថ្មី មិនមែនដោយពូជដែលតែងតែរលួយទេ គឺដោយពូជមិនចេះរលួយ ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលនេះផ្តល់ជីវិត ហើយនៅស្ថិតស្ថេរជាដរាប"

*១ ពេត្រុស ១ : ២៣*

*អានបន្ថែម: ម៉ាកុស ៤ : ៣ - ៩, ១៣ - ២០*

នៅក្នុងខនៃកណ្ឌគម្ពីរនេះ ពេត្រុសប្រាប់យើងថា តាមរយៈគ្រាប់ពូជដែលមិនចេះរីងស្ងួតនៃព្រះបន្ទូលរបស់ព្រះ បានឱ្យយើងបានកើតជាថ្មី។ តើគាត់មានន័យយ៉ាងណាចំពោះរឿងនេះ ? នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងទទួលដំណឹងល្អនៃអ្វីដែលព្រះជាម្ចាស់បានធ្វើតាមរយៈព្រះយេស៊ូវគ្រីស្ទ ដើម្បីសង្គ្រោះយើង។ ហើយវាគឺតាមរយៈដំណឹងល្អដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមនុស្សម្នាក់បានកើតជាថ្មី។ ប៉ុន្តែ ព្រះអង្គមិនគ្រាន់តែបើកបង្ហាញផែនការនៃការសង្គ្រោះតាមរយៈព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះទេ។ ទ្រង់បង្ហាញភាពជាព្រះអង្គផ្ទាល់ដល់យើង។ហេតុនេះហើយ ពេត្រុសហៅថា ព្រះបន្ទូលដ៏មានព្រះជន្មគង់នៅ។

ពេត្រុសបានប្រៀបធៀបព្រះបន្ទូលព្រះជាម្ចាស់ទៅនឹងគ្រាប់ពូជដែលមិនឲសាបសូន្យ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍អំពីគ្រាប់ពូជនោះគឺថា វាស្ងួត និងរិលដោយមានភស្តុតាងតិចតួចណាស់អំពីជីវិតរបស់វាមុនពេលអ្នកដាំវា។ ប៉ុន្តែនៅពេលដែលវាស្ថិតក្នុងស្ថានភាពត្រឹមត្រូវ ដាំក្នុងដីសើម និងសម្បូរសារធាតុចិញ្ចឹម វាផុសចេញឡើងនូវជីវិតនៃរុក្ខជាតិ នៅពេលដែលយើងរង់ចាំយ៉ាងអន្ទះសារពីលើផ្ទៃខាងលើ យើងឃើញសញ្ញានៃជីវិតទាំងនោះលេចចេញមក។ ដូចជាគ្រាប់ពូជដែលដាំក្នុងលក្ខខណ្ឌត្រឹមត្រូវដែរ ព្រះបន្ទូលរបស់ព្រះជាម្ចាស់កំពុងរង់ចាំការដាំនៅក្នុងដីល្អក្នុងការលូតលាស់ខាងជំនឿ។ ហើយបន្ទាប់មកដោយព្រះវិញ្ញាណបរិសុទ្ធព្រះបន្ទូលរបស់ទ្រង់នឹងដុះពន្លក ចាក់ឬស ហើយលូតលាស់ នាំនូវជីវិតនិងភាពស្រស់ស្អាតដល់អ្វីដែលក្រេបយកព្រះបន្ទូលទ្រង់នោះ។ នៅពេលដែលយើងបើកអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ នោះ យើងជួបនឹងព្រះជាម្ចាស់នៃសកលលោក ទ្រង់ជាអ្នកបង្កើតអ្វីៗទាំងអស់ ហើយក៏កំពុងបង្កើតអ្វីៗទាំងអស់ឲ្យថ្មីផងដែរ។

ហើយពេលដែលយើងជួបជាមួយទ្រង់ ជីវិតរបស់យើងត្រូវបានផ្លាស់ប្តូរទាំងស្រុង។ ប្រហែលជាមានផ្នែកខ្លះនៃជីវិតរបស់អ្នកពេញដោយភាពស្ងួតហួតហែង។ ប្រហែលជាសេចក្តីស្រឡាញ់របស់អ្នកចំពោះអ្នកដែលវង្វេងបានសាបសូន្យ ឬ ចំណង់ចិត្តអ្នកចំពោះបេសកកម្មរបស់ព្រះជាម្ចាស់ត្រូវបានរលត់។ ព្រះបន្ទូលដែលមានព្រះជន្មគង់នៅ និងស្ថិតស្ថេររបស់ព្រះជាម្ចាស់នឹងមិនបាត់បង់អំណាចរបស់វាសោះឡើយ ក្នុងការបំពេញគ្រប់កន្លែងដែលរិចរិល ស្ងួត និង ស្លាប់ក្នុងជីវិតរបស់អ្នក ដោយព្រះបន្ទូលធ្វើឱ្យ ផ្ទុះឡើងជាមួយនឹងជីវិតថ្មីដែលស្ថិតស្ថេរ និងអស់កល្បជានិច្ច។ ហើយនៅពេលដែលព្រះបន្ទូលរបស់ទ្រង់បានប៉ះពាល់ និងផ្លាស់ប្តូរជីវិត របស់យើង យើងមិនអាចជួយអ្វីបានក្រៅពីការសាបព្រួសគ្រាប់ពូជដែលមិនចេះរីងស្ងួតនេះដោយធ្វើការចែកចាយដំណឹងល្អអំពីអ្វីដែលព្រះយេស៊ូវបានធ្វើដើម្បីសង្គ្រោះយើង ទោះយើងទៅទីណាក៏ដោយ។

សូមគិតអំពីពេលដែលអ្នកបានឮដំណឹងល្អជាលើកដំបូង។ តើមាននរណាម្នាក់ចែករំលែកវាជាមួយអ្នកទេ? សូមសញ្ជឹងគិតពីគ្រានោះ ដោយអរព្រះគុណព្រះសម្រាប់ការសង្គ្រោះរបស់ទ្រង់។

---

---

---

ដោយសារព្រះបន្ទូលទ្រង់គឺមានព្រះជន្មគង់នៅ និងស្ថិតស្ថេរផងនោះ តើផ្នែកណាខ្លះនៃជីវិតរបស់អ្នកត្រូវចាប់ផ្តើមសារជាថ្មីនៅសប្តាហ៍នេះ?

---

---

---

*ព្រះបន្ទូលព្រះជាម្ចាស់ធ្វើឱ្យអ្វីៗទាំងអស់ថ្មីឡើងវិញ។*

ព្រះជាម្ចាស់បានប្រោសបងប្អូនអោយកើតជាថ្មី មិនមែនដោយពូជដែលតែងតែរលួយទេ គឺដោយពូជមិនចេះរលួយដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលនេះផ្ដល់ជីវិត ហើយនៅស្ថិតស្ថេរជាដរាប

១ ពេត្រុស ១:២៣

ឱព្រះជាម្ចាស់អើយ ទូលបង្គំជឿថា
ព្រះបន្ទូលទ្រង់គឺជាគ្រាប់ពូជដែលមិនសាបសូន្យ
ដែលអាចឲ្យគ្រប់ផ្នែកទាំងអស់លូតលាស់នៃក្នុងជីវិតរបស់កូន។
ទូលបង្គំសូមថ្វាយ ការបែកបាក់ ការភាន់ច្រឡំ និង ភាពអសន្តិសុខ ទៅកាន់ទ្រង់
ដោយដឹងថាព្រះអង្គ ធ្វើឱ្យទូលបង្គំមានសុខភាពល្អ មានទំនុកចិត្ត
និងសុវត្ថិភាពតាមរយៈគ្រាប់ពូជនៃព្រះបន្ទូលរបស់ទ្រង់។ ទ្រង់បាននាំខ្ញុំពីសេចក្ដី
ស្លាប់ ឲ្យមានជីវិត ហើយស្មោះត្រង់ ដើម្បីបញ្ចប់កិច្ចការល្អដែលព្រះអង្គបាន
ចាប់ផ្ដើមក្នុងជីវិតទូលបង្គំ។ ព្រះអម្ចាស់ ទូលសូមបង្គំអធិស្ឋាន
សូមទ្រង់បន្តផ្លាស់ប្តូរជីវិតទូលបង្គំ
ដើម្បីឆ្លុះបញ្ចាំងពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ ចំពោះអ្នកជុំវិញទូលបង្គំ។
ដោយសារតែព្រះបន្ទូលរបស់ព្រះអង្គបានដាំនៅក្នុងជីវិតខ្ញុំ ឲ្យខ្ញុំ
មានភាពក្លាហានក្នុងការចែកចាយដំណឹងល្អអំពីព្រះនាមទ្រង់គ្រប់ទីកន្លែងដែល
ខ្ញុំទៅ។

អាម៉ែន!

# ថ្ងៃទី ២

# ព្រះបន្ទូលគឺជាពន្លឺ



***ចូរអាន ទំនុកតម្កើង ១១៩:១០៥–១១២***

ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជំហានទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ។
***ទំនុកតម្កើង ១១៩:១០៥***
***ខគម្ពីរបន្ថែម ទំនុកតម្កើង ១១៩:១៣០***

***ទំនុកតម្កើង ១១៩*** គឺជាទំនុកតម្កើងដ៏ឈ្លាសវៃពោរពេញទៅដោយព្រះបញ្ញា ដែលពន្យល់ពីព្រះបន្ទូលរបស់ព្រះជាការណែនាំដ៏ល្អឥតខ្ចោះសម្រាប់ជីវិត។ នៅក្នុង ខ ១០៥ អ្នកតែងទំនុកតម្កើងនិយាយថា ព្រះបន្ទូលរបស់ព្រះជាចង្កៀងបំភ្លឺជំហាន ហើយជាពន្លឺដល់ផ្លូវទ្រង់។ នៅសម័យបុរាណភាគបូព៌ា ចង្កៀងមួយគឺដូចជាចានតូចមួយដែលមានអំបោះសម្រាប់ដុត។ ការចាក់ប្រេងពេញចាន អ្នកនឹងបំភ្លឺអំបោះ ដោយផ្តល់ពន្លឺគ្រប់គ្រាន់ដើម្បីបំភ្លឺផ្លូវងងឹត។

នៅពេលយើងឆ្លងកាត់ជីវិត ជារឿយៗយើងប្រឈមមុខនឹងស្ថានភាពហួសពីសមត្ថភាពរបស់យើងក្នុងការរុករកការសម្រេចចិត្តដែលយើងត្រូវធ្វើ កាលៈទេសៈលំបាកដែលយើងប្រឈមមុខ គំនិត និង មនោគមន៍វិជ្ជាដែលយើងត្រូវតស៊ូ។ យើងព្យាយាមដោះស្រាយដោយខ្លួនឯង ប៉ុន្តែដោយគ្មានការណែនាំ យើងតែងជំពប់ដួលក្នុងភាពងងឹត។ យើងត្រូវការពន្លឺដ៏គួរឱ្យទុកចិត្ត ដើម្បីបំភ្លឺផ្លូវងងឹតនៅពីមុខយើង។

នៅក្នុងព្រះបន្ទូលរបស់ព្រះ យើងតែងតែរកឃើញការណែនាំបែបនេះ។ នៅក្នុង ***២ ធីម៉ូថេ ៣:១៦*** លោកប៉ូលបានប្រាប់យើងថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះ ដែលមានន័យថា ពាក្យដែលមាននៅក្នុងព្រះគម្ពីរគឺមកពីព្រះជាម្ចាស់។ តើអ្នកមាននរណាម្នាក់ក្នុងជីវិតរបស់អ្នកដែលអាចជឿទុកចិត្តបានពេលគេប្រាប់អ្នកពីអ្វីមួយ អ្នកជឿទុកចិត្តពាក្យគេដោយគ្មានសំណួរ ឬការសួរដេញដោល? អ្នកអាចជឿទុកចិត្តពួកគេបានដោយសារតែចរិតលក្ខណៈរបស់ពួកគេបានបង្ហាញឱ្យអ្នកឃើញតាមរយៈពេលវេលាដែលយើងបានចំណាយពេល ឬការកត់សំគាល់ថាពួកគេគួរឱ្យទុកចិត្ត។ ហើយប្រសិនបើយើងអាចទុកចិត្តពាក្យសម្តីរបស់មនុស្សម្នាក់ ចុះទំរាំតែពាក្យរបស់ព្រះដ៏ល្អឥតខ្ចោះដែលបានបញ្ជាក់ម្តងហើយម្តងទៀតថាទ្រង់ល្អតើយើងអាច

ទុកចិត្តបានទេ? ព្រះបន្ទូលរបស់ព្រះគឺជាការណែនាំដ៏គួរឱ្យទុកចិត្ត និងពិតប្រាកដ ពីព្រោះព្រះជាម្ចាស់ទ្រង់ជាមគ្គុទ្ទេសក៍ដ៏គួរឱ្យទុកចិត្ត និងគួរឱ្យទុកចិត្ត។

បច្ចុប្បន្នអ្នកអាចប្រឈមមុខនឹងស្ថានភាពហួសពីសមត្ថភាពរបស់អ្នកក្នុងការស្វែងរកការសម្រេចចិត្តដែលអ្នកត្រូវធ្វើ ឬកាលៈទេសៈដ៏លំបាកដែលអ្នកត្រូវឆ្លើយតប។ ព្រះបន្ទូលរបស់ព្រះគឺជាពន្លឺភ្លឺដើម្បីដឹកនាំផ្លូវងងឹតរបស់អ្នក ហើយផ្តល់ឲ្យអ្នកនូវប្រាជ្ញាដែលអ្នកត្រូវការ។
ហើយមិនត្រឹមតែព្រះបន្ទូលរបស់ព្រះនឹងផ្តល់ឱ្យអ្នកនូវប្រាជ្ញាប៉ុណ្ណោះទេប៉ុន្តែក្នុងការស្តាប់តាមនិងអនុវត្តព្រះបន្ទូលរបស់ព្រះអ្នកនឹងរីកចម្រើនជាមនុស្សដែលមានប្រាជ្ញាដែលអាចបំភ្លឺពន្លឺនៅក្នុងពិភពលោកដ៏ងងឹតមួយ។

សូមគិតអំពីគ្រាមួយដែលព្រះបន្ទូលរបស់ព្រះបានប្រទានប្រាជ្ញាដល់អ្នកក្នុងពេលមានស្ថានភាពលំបាក។ ចំណាយពេលអរព្រះគុណចំពោះការណែនាំរបស់ទ្រង់។

សរសើរតម្កើងព្រះថា ទ្រង់អាចទុកចិត្តបាន និងគួរឱ្យទុកចិត្ត។ តើមានផ្នែកណាមួយក្នុងជីវិតរបស់អ្នកដែលអ្នកអាចទុកចិត្តព្រះបន្ទូលរបស់ព្រះបានកាន់តែប្រសើរសម្រាប់ការណែនាំឬ?

ព្រះបន្ទូលរបស់ព្រះណែនាំយើង។

ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជំហាន
ទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ។
ទំនុកតម្កើង ១១៩:១០៥

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ទ្រង់បានផ្ដល់ឱ្យទូលបង្គំនូវព្រះបន្ទូល
ដ៏ល្អឥតខ្ចោះរបស់ទ្រង់ជាការណែនាំឆ្លងកាត់លោកិយ៍ដែលមិនល្អឥតខ្ចោះនេះ។
ដោយសារតែទ្រង់ជាព្រះដ៏ល្អ គួរឱ្យទុកចិត្ត ចេះគ្រប់ជ្រុងជ្រោយ និងមានព្រះទ័យល្អ
ហើយទូលបង្គំអាចពឹងផ្អែកលើការណែនាំរបស់ទ្រង់គ្រប់ស្ថានភាពដែលទូលបង្គំជួ
បប្រទះ។ ទ្រង់តែងតែខ្វល់អំពីជីវិតរបស់ទូលបង្គំ
និងការសម្រេចចិត្តដែលទូលបង្គំត្រូវធ្វើ។ ពាក្យរបស់ទ្រង់មានអានុភាពទៅលើ
ភាពវឹកវរ ហើយជាពន្លឺក្នុងភាពងងឹត។ ទូលបង្គំគ្មានហេតុផលត្រូវខ្លាចទេ។
នៅពេលទូលបង្គំដាក់ព្រះបន្ទូលរបស់ទ្រង់យ៉ាងជ្រៅក្នុងចិត្តទូលបង្គំ
ព្រះបន្ទូលទ្រង់បានបង្រៀនទូលបង្គំពីរបៀបអាន
និងយកពាក្យទាំងនោះមកអនុវត្តក្នុងជីវិតទូលបង្គំផងដែរ។

អាម៉ែន!

# ថ្ងៃទី ៣

# ព្រះបន្ទូលគឺជាកញ្ចក់

***ចូរអាន យ៉ាកុប ១:១៩–២៥***
អ្នកណាស្ដាប់ព្រះបន្ទូលហើយ មិនប្រតិបត្តិតាម អ្នកនោះប្រៀបបាននឹងមនុស្សម្នាក់ឆ្លុះកញ្ចក់មើលមុខខ្លួន លុះពិនិត្យមើលរួចហើយក៏ចេញទៅ ស្រាប់តែភ្លេចមិនដឹងថាមុខខ្លួនឯងដូចម្ដេចផង។
***យ៉ាកុប ១:២៣–២៤***

***ខគម្ពីរបន្ថែម រ៉ូម ២:១៣***

លោកយ៉ាកុបបានសរសេរទៅកាន់ជនជាតិយូដាគ្រិស្តសាសនិកដែលខ្ចាត់ខ្ចាយពាសពេញចក្រភពរ៉ូមដែលកំពុងជួបប្រទះនឹងការសាកល្បង ហើយសម្រាប់អ្នកដែលក្នុងអំឡុងពេលនៃការសាកល្បងទាំងនេះ កំពុងធ្វើតាមការអនុវត្តខាងលោកិយរបស់អ្នកដែលនៅជុំវិញពួកគេ ជាជាងការអនុវត្តព្រះបន្ទូលរបស់ព្រះ។ ដូច្នេះហើយក្នុងសំបុត្ររបស់គាត់ លោកយ៉ាកុបបានលើកឡើងថា វាមិនគ្រប់គ្រាន់ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះទេ។ យើងត្រូវតែអនុវត្តតាមព្រញអនុវត្ត។

លោកយ៉ាកុបបានប្រៀបធៀបមនុស្សម្នាក់ដែលស្ដាប់ព្រះបន្ទូល ហើយមិនធ្វើតាមអ្វីដែលគាត់និយាយទៅកាន់មនុស្សម្នាក់ដែលពិនិត្យមើលខ្លួនឯងក្នុងកញ្ចក់ ប៉ុន្តែបន្ទាប់មកដើរចេញហើយភ្លេចថាគាត់មើលទៅដូចអ្វី។ ការប្រៀបធៀបស្ទើរតែមើលទៅហាក់ដូចជាឡូយ។

តើអ្នកមើលខ្លួនឯងឲ្យជិតដើម្បីដឹងថាអ្នកពិតជាមើលទៅយ៉ាងណាហើយដើរចេញរហូតភ្លេចបានយ៉ាងដូចម្ដេច? ប៉ុន្តែនោះជាចំណុចដែលលោកយ៉ាកុប កំពុងព្យាយាមបង្ហាញ។ តើអ្នកពិនិត្យខ្លួនឯងនៅកញ្ចក់នៅពេលព្រឹក ពិនិត្យមើលដើម្បីឱ្យប្រាកដថាសក់របស់អ្នកស្អាត ឬអ្នកមិនមានអ្វីនៅក្នុងធ្មេញទេ? បើអ្នកសង្កេតឃើញស្នាមប្រឡាក់លើមុខអ្នក តើអ្នកនឹងដើរចេញហើយបំភ្លេចវាទេ? វាដូចជាជារឿងល្ងង់ណាស់

ដែលដើរចេញ ហើយមិនធ្វើអ្វីអំពីស្នាមប្រឡាក់លើមុខរបស់អ្នក—ដើម្បីបំភ្លេចនូវរូបរាងរបស់អ្នក—វាជារឿងល្ងង់ខ្លៅដូចគ្នាបន្ទាប់ពីបានពិនិត្យមើលព្រះបន្ទូលរបស់ព្រះដើម្បីដើរចេញ ហើយមិនគោរពតាមវា។

ដូចជាកញ្ចក់ ព្រះបន្ទូលរបស់ព្រះបង្ហាញយើងពីអ្វីដែលជាភាពពិតរបស់យើង។ បើគ្មានព្រះបន្ទូលរបស់ទ្រង់ វាជាការងាយស្រួលក្នុងការបញ្ឆោតខ្លួនយើងឱ្យគិតថាយើងជាអ្វីដែលយើងមិនមែន និងព្រងើយកន្តើយ នឹងភាពទន់ខ្សោយរបស់យើង ហើយរកលេសសម្រាប់អំពើបាបរបស់យើង ជាពិសេស នៅពេល ដែលយើងស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកដូចជាទស្សនិកជនរបស់លោកយ៉ាកុប ។ ប៉ុន្តែ នេះមិនអាចទៅរួចទេ ពេលយើងកាន់ខ្ជាប់នូវព្រះបន្ទូលរបស់ព្រះក្នុងជីវិតរបស់យើង។

នៅពេលយើងពិនិត្យមើលជីវិតរបស់យើងដោយសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះយើងឃើញនូវអ្វីដែលយើងពិតជាដូចហើយយើងជួបជាមួយនឹងព្រះគុណនិងសេចក្តីមេត្តាករុណារបស់ព្រះដើម្បីប្រែចិត្តហើយត្រូវបាន

ផ្លាស់ប្តូរ។

យើងត្រូវសិក្សាព្រះបន្ទូលរបស់ព្រះដើម្បីឱ្យវាអាចបង្ហាញយើងថាយើងជានរណាប៉ុន្តែយើងមិនអាចឈប់នៅទីនោះបានទេ។ បន្ទាប់មក យើងត្រូវតែដើរចេញ ហើយអនុវត្តព្រះបន្ទូលរបស់ព្រះជានិច្ច។

តើអ្នកបានឃើញព្រះគុណ និងព្រះហឫទ័យមេត្តាករុណារបស់ព្រះនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា ?

---

---

---

តើមានផ្នែកដែលអ្នកស្ទាក់ស្ទើរក្នុងការអនុវត្តព្រះបន្ទូលរបស់ព្រះដែរឬទេ ? សូមចំណាយពេលបន្តិចដើម្បីសរសើរទ្រង់ចំពោះសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ទ្រង់ចំពោះអ្នក។

---

---

---

*ព្រះបន្ទូលរបស់ព្រះបង្ហាញថាយើងជាអ្នកណា។*

អ្នកណាស្ដាប់ព្រះបន្ទូលហើយ មិនប្រតិបត្តិតាម អ្នកនោះប្រៀប
បាននឹងមនុស្សម្នាក់ឆ្លុះកញ្ចក់មើលមុខខ្លួន លុះពិនិត្យមើលរួច
ហើយក៏ចេញទៅ ស្រាប់តែភ្លេចមិនដឹងថាមុខខ្លួនឯងដូចម្ដេចផង។
យ៉ាកុប ១:២៣-២៤

នៅពេលដែលទូលបង្គំបានអានព្រះបន្ទូលរបស់ទ្រង់ ឱព្រះអម្ចាស់
ទូលបង្គំជឿជាក់និងទុកចិត្តថា ទ្រង់នឹងបង្ហាញទូលបង្គំភាពខាងក្នុងរបស់ទូលបង្គំ
និងអ្វីដែលទ្រង់ធ្វើមកកាន់ជីវិតទូលបង្គំ។ ចូរទ្រង់ស្វែងរកដួងចិត្តរបស់ទូលបង្គំ
ហើយបង្ហាញកន្លែងដែលទូលបង្គំត្រូវការនិងខ្វះខាត
ដើម្បីអនុវត្តនូវព្រះបន្ទូលរបស់ទ្រង់នៅក្នុងជីវិតរបស់ទូលបង្គំ។ សូមទ្រង់ផ្ដល់
នូវភាពក្នុងការបន្ទាបខ្លួនដល់ទូលបង្គំដើម្បីធ្វើតាមព្រះបន្ទូលរបស់ទ្រង់ជាការ
ឆ្លើយតបដោយសេចក្ដីជំនឿចំពោះអំណោយទាននៃសេចក្ដីសង្គ្រោះដោយឥត
គិតថ្លៃរបស់ទ្រង់។ ទូលបង្គំសូមអរព្រះគុណដល់ព្រះវិញ្ញាណដ៏វិសុទ្ធ
ចំពោះព្រះចេស្ដារបស់ទ្រង់ ដែលជួយទូលបង្គំឱ្យស្ដាប់បង្គាប់
ផ្លាស់ប្ដូរចិត្តរបស់ទូលបង្គំនិងដឹកនាំជំហានរបស់ទូលបង្គំ
នៅក្នុងព្រះនាមព្រះយេស៊ូវ។

អាម៉ែន!

# ថ្ងៃទី៤

# ព្រះបន្ទូលគឺជាញញួរ

***សូមអាន យេរេមា ២៣:២៣-៣២***

ពាក្យរបស់យើងប្រៀបបីដូចជាភ្លើង និងដូចញញួរបំបែកថ្ម-នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
***យេរេមា២៣:២៩***

***សូមអានបន្ថែមនៅ កិច្ចការ ២:៣៧-៣៨***

នៅគ្រាដ៏រីករាយរបស់ជាតិសាសន៍យូដា ព្យាការីយេរេមាបានរស់នៅទីនោះសម្រាប់ពួកគេ។ គាត់ចាប់ផ្តើមអាជីពរបស់គាត់ជាព្យាការី ក្នុងរជ្ជកាលស្តេច យ៉ូ សៀស ដែលជាស្តេចស្មោះត្រង់ចុងក្រោយបង្អស់ ហើយគាត់បានបន្តព្យាករណ៍ក្នុងកំឡុងឆ្នាំចុងក្រោយមុនពេលក្រុងយេរូសាឡឹមត្រូវបានបំផ្លាញដោយនេបូក្នេសា ហើយប្រជាជនត្រូវបាននាំយកទៅធ្វើជាឈ្លើយនៅបាប៊ីឡូន។

ពេញមួយពន្ធកិច្ចរបស់ព្យាការី យេរាមា គាត់បានប្រកាសនូវសារដ៏ជូចត់ដែលថាការជំនុំជំរះនឹងមកដល់ ដោយអំពាវនាវអោយប្រជាជនទាំងអស់ងាកចេញពីមាគ៌ាអាក្រក់ និងការថ្វាយបង្គំរូបព្រះក្លែងក្លាយ ហើយត្រឡប់ទៅថ្វាយបង្គំដ៏បរិសុទ្ធនៃព្រះពិតតែមួយវិញ។ ប៉ុន្តែពួកគេមិនបានស្តាប់នូវការប្រកាសរបស់លោកយេរាមាទ្បើយ។ផ្ទុយទៅវិញពួកគេបានជ្រើសរើសស្តាប់ព្យាការីក្លែងក្លាយជាបុរសដែលប្រកាសសារដ៏ទាក់ទាញ ដែលឆ្លុះបញ្ចាំងពីអ្វីដែលប្រជាជនចង់លឺ ជាជាងការប្រកាសអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ផ្ទុយពីពាក្យឥតប្រយោជន៍និងឥតបានការទាំងនេះព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាញញួរដែលអាចបំបែកថ្មដែររឹង ហើយក្រាំងបំផុតទៅជាបំណែក។

នៅពេលដែរអ្នកឃើញពាក្យថា"ញញួរ"អ្នកប្រហែលជាគិតអំពីញញួររបស់ជាងឈើដែលត្រូវបានប្រើនៅក្នុងគម្រោងសាងសង់ ហើយភាគច្រើនជា ការសាងសង់ផ្ទះដូចជាការដំដែកគោលចូលទៅក្នុងវត្ថុមួយ។ ប៉ុន្តែនៅក្នុងបរិបទនេះវាជាការប្រសើរក្នុងការគិតអំពីញញួររបស់ជាងដែកដែលប្រើសម្រាប់ដំលោហៈដើម្បីអោយក្លាយទៅជារូបរាងឬទ្រង់ទ្រាយអ្វីមួយ ហើយនៅពេលដែលប្រើវាដោយកម្លាំងខ្លាំងគឺវាអាចកម្ទេច និងបំបែកវត្ថុណាមួយ។

ត្បិតយើងដើរជាមួយព្រះយេស៊ូ តែដួងចិត្តដែលរឹងទទឹងក៏នឹងអាចកើតមានដែរ។ ទាំងនេះអាចកើតឡើងតាមរយៈអំពើបាបដោយសម្ងាត់ដែលយើងមិនបានសារភាពទៅកាន់ទ្រង់ ភាពជូរចត់ដែលកើតចេញពីការមិនអត់ឱនទោស ឬភាពឃោរឃៅដែលចូលមកក្នុងចិត្តរបស់យើង នៅពេលដែលការអធិស្ឋានរបស់យើងមិនទទួលបាននៅការឆ្លើយតប។ ដោយស្ថិតនៅក្នុងស្ថានភាពបែបនេះគឺយើងជ្រើសរើសបណ្តែតបណ្តោយខ្លួន និងចំណាយពេលលើប្រព័ន្ធផ្សព្វផ្សាយសង្គមការអានព័ត៌មានអវិជ្ជមានតាមអ៊ីនធឺណិតនិងការមើលទូរទស្សន៍ដោយឥតប្រយោជន៍ច្រើនជាងការចំណាយពេលជាមួយព្រះជាម្ចាស់ និងប្រតិបត្តិតាមព្រះបន្ទូលរបស់ទ្រង់។ ប៉ុន្តែនៅពេលដែលយើងបើកព្រះបន្ទូលនៃព្រះនោះយើងនឹងទទួលបាននូវបទពិសោធន៍ដែលជាឥទ្ធិពលដ៏អស្ចារ្យនៃញញួររបស់ទ្រង់ដែលអាចកំទេច និងបំបែកអំពើបាបដែលជាភាពជូរចត់និងដួងចិត្តដែលរឹងទទឹងរបស់យើង នៅពេលដែរយើងឆ្លើយតបដោយបន្ទាបខ្លួន និងកែប្រែចិត្តគំនិតទាំងស្រុងនៅចំពោះព្រះភ័ក្ត្រទ្រង់។

តើអ្នកមានបទពិសោធន៍យ៉ាងណាដែលនៅពេលដែលព្រះបន្ទូលរបស់ទ្រង់បានបន្ទន់ដួងចិត្តរបស់អ្នក? ចូរអរព្រះគុណទ្រង់សម្រាប់អំណាចនៃការផ្លាស់ប្តូរដួងចិត្តរបស់អ្នក។

តើមានគ្រាពិសេស ឬការលំបាកណាដែលបណ្តាលឲ្យអ្នកដើរតាម «ព្យាការីក្លែងក្លាយ» ជាជាងងាកទៅរកព្រះបន្ទូលរបស់ព្រះឬទេ?

## *មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលនឹងបន្ទន់ដួងចិត្តរបស់យើង។*

ពាក្យរបស់យើងប្រៀបបីដូចជាភ្លើង
និងដូចញញួរបំបែកថ្ម-
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
យេរេមា២៣:២៩

បិតាអើយ ទ្រង់ដឹងពីដួងចិត្តកូនជាងអ្នកណាទាំងអស់
ព្រះអង្គបានស្រលាញ់កូនបើទោះបីជាកូនវង្វេងឆ្ងាយពីទ្រង់ក៏ដោយ
ព្រះអង្គបានបង្ហាញអោយកូនឃើញនូវរបៀបដែលកូនបានឃ្លាតឆ្ងាយពីទ្រង់
ហើយនាំកូនមកត្រឡប់មកវិញដោយដាក់កូននៅកន្លែងដែលរឹងមាំ។
ព្រះអង្គអើយកូនសូមសារភាពនូវទង្វើដែលកូនបានដាក់សេចក្តីជំនឿទៅលើលោកីយ៍ជាជាងព្រះបន្ទូលរបស់ទ្រង់។
ព្រះបន្ទូលរបស់ទ្រង់មានអំណាចក្នុងការផ្លាស់ប្តូរដួងចិត្តដែលរឹងដូចថ្មអោយក្លាយទៅជាទន់។ កូនបើកដួងចិត្តកូនដោយអនុញ្ញាត្តិអោយទ្រង់សូនកូន។
ព្រះអង្គអើយដូចដែលទ្រង់បានបន្ទន់ចិត្តកូន
សូមជួយពង្រឹងកូនដើម្បីអោយកូននាំយកនូវព្រះបន្ទូលរបស់ប្ទង់ទៅកាន់បុគ្គលគ្រប់រូបនៅជុំវិញខ្លួនកូន នៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ទ

អាម៉ែន!

# ថ្ងៃទី៥



# ព្រះបន្ទូលគឺជាដាវ

*សូមអាន ហេព្រើ ៤:១-១២*
*ហេព្រើ ៤:១២* "ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត
និងមានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង
និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ
និងគំនិតនៅក្នុងជម្រៅចិត្តមនុស្ស។"

***សូមអានបន្ថែមនៅខគម្ពីរ អេភេសូ ៦:១៣-១៧***

ឈានដល់ ***ហេព្រើ ៤:១២*** អ្នកនិពន្ធនិយាយអំពីថ្ងៃឈប់សម្រាកដែលព្រះជាម្ចាស់មានសម្រាប់យើង។ នៅពេលដែរថ្ងៃសប្ប័ទនេះត្រូវបានផ្តល់ដល់ជនជាតិអ៊ីស្រាអែល ការមិនស្តាប់បង្គាប់និងការមិនជឿរបស់ពួកគេបានរារាំងពួកគេមិនឱ្យចូលទៅក្នុងពិធីនោះឡើយ។ ឥឡូវនេះការឈប់សម្រាកថ្ងៃសប្ប័ទ នេះត្រូវបានផ្តល់ជូនដល់អស់អ្នក ដែលមានជំនឿក្នុងព្រះគ្រីស្ទ ប៉ុន្តែអ្នកនិពន្ធនៃភាសាហេប្រើ បានរំលឹក ដាស់តឿនយើងកុំឱ្យយកតម្រាប់ដូចជាពួកអ៊ីស្រាអែលបានធ្វើឡើយ ដើម្បីកុំឱ្យយើងធ្លាក់ចូលក្នុងទង្វើដែល មិនស្តាប់បង្គាប់ទ្រង់ដូចគ្នា។ បន្ទាប់មកអ្នកនិពន្ធភាសាហេប្រឺបាន និយាយអំពីអំណាចនៃ ព្រះបន្ទូល របស់ព្រះជាម្ចាស់ ដោយប្រៀបធៀបវាទៅនឹងដាវមុខពីរ។ ចំពោះដាវគឺ មានប្រភេទដាវផ្សេងៗគ្នា ដែលនីមួយៗ ត្រូវបានរចនាឡើងសម្រាប់គោលបំណងផ្សេងៗគ្នា។ ( ដោយមួយចំនួនប្រើសម្រាប់កម្លាំងខណៈដែលមួយ ចំនួនទៀតប្រើសម្រាប់ភាពត្រឹមត្រូវ )។ ដាវមុខពីរដែលមុតទាំងសងខាងត្រូវបានរចនាឡើង យ៉ាងពិសេសដើម្បីទម្លុះមុខសញ្ញាវាដោយភាពជាក់លាក់។ យើងបានរៀនពីសៀវភៅ យ៉ាកុប ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្ហាញយើងពីអ្វីដែលយើងត្រូវធ្វើ ហើយដូចដែលយើងបានរៀនពីយេរេមាផងដែរ គឺព្រះបន្ទូលរបស់ទ្រង់មានអំណាចដើម្បីកំទេចដួងចិត្តដែលរឹងរូសពីអំពើបាបរបស់យើង។ ឥឡូវនេះ នៅក្នុងសៀវភៅហេប្រឺ យើងរកឃើញថា ព្រះបន្ទូល របស់ព្រះជាម្ចាស់ គឺជាដាវមុខពីរ ដែលអាចទម្លុះផ្នែកនៃព្រលឹង និងវិញ្ញាណ សន្លាក់ និងខួរឆ្អឹង។ ទាំងនេះគឺមានន័យថា វាអាចជ្រាបចូលទៅក្នុងស្នូល និងខ្លឹមសារនៃជម្រៅជីវិតរបស់យើង។ ប៉ុន្តែអ្នកនិពន្ធ ក៏ និយាយដែរថា

ព្រះបន្ទូលរបស់ទ្រង់គឺមានជីវិតគង់នៅ និងសកម្ម មានន័យថា វាមិនគ្រាន់តែចាក់ទម្លុះ បេះដូង របស់យើង បង្ហាញអោយយើងឃើញថាយើងជានរណានិងកាត់ទោសយើងពីអំពើបាបរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែវាមានអំណាចដើម្បីផ្លាស់ប្តូរយើងពីខាងក្នុងចេញមកខាងក្រៅ។ នៅពេលដែលយើងរស់នៅដោយសេចក្តីសង្គ្រោះនៅក្នុងព្រះយេស៊ូវ នោះយើងមិនចង់អោយខ្លួនយើងធ្លាក់ចុះ ដោយការមិនស្តាប់បង្គាប់ និងការមិនមានជំនឿដូចដែលជនជាតិអ៊ីស្រាអែលបានធ្វើនៅក្នុងទីរហោស្ថាននោះទេ។ ប៉ុន្តែនៅពេលយើងអានព្រះបន្ទូល ដែលមានជីវិតគង់នៅ និងសកម្ម នោះគឺមានន័យថាដាវមុខពីរនេះនឹងចាក់ទម្លុះយើង ដោយបង្ហាញ យើង នូវអ្វីដែលពិតជានៅក្នុងចិត្តរបស់យើង ហើយផ្លាស់ប្តូរយើងកាន់តែច្រើនអោយទៅជារូបតំណាងរបស់ព្រះគ្រីស្ទ នៅពេលដែលយើងឆ្លើយតបដោយការប្រែចិត្តគំនិត និងដាក់នូវសេចក្តីជំនឿទៅកាន់ទ្រង់ទាំងស្រុង។

សេចក្តីជំនឿ និងការប្រែចិត្ត គឺជាអំណោយទានពីព្រះជាម្ចាស់ ដែលនាំយើងឱ្យខិតទៅជិតទ្រង់។
តើអ្នកបានអរព្រះគុណទ្រង់សម្រាប់អំណោយទានទាំងនេះទេ ?

---

---

---

តើផ្នែកណាមួយនៅក្នុងជីវិតរបស់អ្នក ដែរអ្នកមានជំនឿថាព្រះបន្ទូលរបស់ទ្រង់នឹងផ្លាស់ប្តូរផ្នែកទាំងនោះបាន ?

---

---

---

*ព្រះបន្ទូលរបស់ទ្រង់អាចកែប្រែ*
*និងផ្លាស់ប្តូរយើងបានទាំងស្រុង។*

"ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត
និងមានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូល
នេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា
កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ
និងគំនិតនៅក្នុងជម្រៅចិត្តមនុស្ស។"
ហេប្រឺ ៤:១២

បិតាអើយកូនសូមអរគុណសម្រាប់ព្រះបន្ទូលដែលមានព្រះជនគង់នៅ
ដែលមានអំណាចក្នុងការកែប្រែជីវិតរបស់កូនទាំងស្រុង
កូនជ្រើសភ្ជាប់ខ្លួនជាមួយព្រះបន្ទូលទ្រង់
ទាំងផ្នែកដែលពិបាកបំផុតនៅក្នុងជម្រៅដួងចិត្តកូន។
កូនទទួលស្គាល់កំហុសគ្រប់យ៉ាង ហើយសូមអោយទ្រង់ផ្លាស់ប្តូរ
នូវគមនិតនិងដួងចិត្តកូន
រាល់ពេលដែលកូនសញ្ជឹងគិតពីព្រះបន្ទូលទ្រង់ជារៀងរាល់ថ្ងៃ។
បង្កើននូវជមនឿរបស់កូន ដើម្បីអោយកូនបានដូចជាទ្រង់
អាម៉ែន!

# ជារួមមក

# ព្រះបន្ទូលគឺជា គ្រឹះដ៏រឹងមាំរបស់យើង

***សូមអាន ម៉ាថាយ ៧:២៤-២៧***

***ម៉ាថាយ ៧:២៤*** "«អ្នកណាស្ដាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម។"

***សូមអានបន្ថែមនៅ ១ពេត្រុស ២: ៤-១០***

នៅពេលដែលព្រះជាម្ចាស់នៅលើភ្នំ ទ្រង់មានបន្ទូលជាមួយពួកសិស្សរបស់ទ្រង់និងហ្វូងមនុស្សអំពីជីវិត ដែលយើងគួរស់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ បន្ទាប់ពីទ្រង់មានព្រះបន្ទូលចប់សព្វគ្រប់ហើយគឺ ទ្រង់សួរពួកសិស្សថា៖តើអ្នកនឹងក្លាយជាអ្នកសាងសង់ដ៏ឈ្លាសវៃហើយជ្រើសរើសសាងសង់ជីវិតរបស់អ្នកនៅលើ ថ្មដ៏រឹងមាំនៃពាក្យរបស់ខ្ញុំ ឬមួយអ្នកនឹងធ្វើជាអ្នកសាងសង់ដ៏ល្ងង់ខ្លៅ ហើយមិនគោរពពាក្យខ្ញុំ ដោយជ្រើសរើសសាងសង់ជីវិតអ្នកនៅលើខ្សាច់។ ប្រសិនបើអ្នករស់នៅកន្លែងណាដែលមានទឹកជំនន់ញឹកញាប់ នោះមានន័យថាឧទាហរណ៍ដែលព្រះជាម្ចាស់ប្រើក្នុងការសាងសង់ជីវិតរបស់អ្នកនៅលើគ្រឹះដ៏រឹងមាំនឹងបង្ហាញ ហើយផ្ទះបញ្ជាំងមកកាន់អ្នក។ ក្នុងពេលតែប៉ុន្មាននាទីប៉ុណ្ណោះ ភ្លៀងធ្លាក់ដ៏ខ្លាំងអាចកម្ទេចនិងបំផ្លាញផ្ទះដែលធ្លាប់តែជាផ្ទះដ៏ស្រស់ស្អាតពីមុន។ នៅពេលដែលមានព្យុះគឺបង្ហាញពីស្ថានភាពគ្រឹះនៃអគារមួយ ដូចទៅនឹងព្យុះនៃជីវិតគឺបង្ហាញថាតើយើងបានសាងសាងជីវិតរបស់យើងនៅលើគ្រឹះដ៏រឹងមាំនៃព្រះបន្ទូលរបស់ទ្រង់ដែរឬទេ។ នៅសប្ដាហ៍នេះយើងបានសិក្សាពីព្រះបន្ទូលរបស់ទ្រង់គឺដូចជានំប៉ុងដែលចាំបាច់សម្រាប់អាហារបំប៉នខាងវិញ្ញាណរបស់យើង ដែលជាគ្រាប់ពូជដែលបានដាំនៅក្នុងចិត្តរបស់យើង ហើយបង្កើតផល ជាពន្លឺបំភ្លឺផ្លូវរបស់យើង ហើយដឹកនាំយើងទៅកាន់ប្រាជ្ញាទាំងអស់ ដែលជាកញ្ចក់បង្ហាញយើងថាយើងពិតជានរណា និងជាញញួរដែលអាចកំទេចដួងចិត្តដែលរឹងរូសពីអំពើបាបរបស់យើង ហើយជាដាវដែលអាចទម្លុះដល់ស្នូល និងជម្រៅដួងចិត្តនៃយើងពិតជានរណា ហើយមានអំណាចអាចផ្លាស់ប្ដូរជីវិតរបស់យើង។

សំណួរសួរថា តាមរយៈការតមអាហារនេះ តើអ្នកនឹងធ្វើអ្វីបន្ត ? តើអ្នកនឹងក្លាយជាអ្នកសាងសង់ដ៏ឈ្លាសវៃ ដែលសាងសង់ជីវិតរបស់អ្នកលើគ្រឹះដ៏រឹងមាំឬ យ៉ាងណា ?
ខណៈពេលដែលសប្តាហ៍នេះគឺជាពេលវេលាដ៏អស្ចារ្យនៃការជួបជុំគ្នា ដែលយើងគ្រប់គ្នាទទួលបាននូវបទពិសោធន៍ជាមួយព្រះជាម្ចាស់ ហើយបានឮនូវព្រះសូរសៀងទ្រង់ យ៉ាងណាមិញការចូលរួមក្នុងការតមអាហារប្រចាំឆ្នាំរយៈពេលប្រាំថ្ងៃនេះគឺមិនគ្រប់គ្រាន់ឡើយសម្រាប់អ្នកដើម្បីសាងសង់ជីវិតរបស់អ្នកនៅលើគ្រឹះដ៏រឹងមាំនោះទេ។ វាស្ថិតនៅក្នុងរបៀប និងទម្លាប់រស់នៅរបស់អ្នកប្រចាំថ្ងៃ ដូចជាការអានប្រចាំថ្ងៃ និងការគោរពតាមព្រះបន្ទូលរបស់ទ្រង់ទើបអ្នកអាចសាងសង់ជីវិតនៅលើគ្រឹះដ៏រឹងមាំដែលព្យុះនៃជីវិតមិនអាចបំផ្លាញអ្នកបានឡើយ។

ការនៅជាប់នឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ គឺជាការស្ថិតនៅជាប់ជាមួយទ្រង់ ដែរជាព្រះបន្ទូលនៃព្រះដ៏មានព្រះជន្មរស់។ តើព្រះយេស៊ូវជាគ្រឹះដែលជីវិតរបស់អ្នកត្រូវបានសាងសង់ឬទេ ?

---

---

---

ពាក្យ «នៅជាប់» មានន័យថា «រក្សាស្ថិរភាព ឬស្ថិតស្ថេរក្នុងស្ថានភាពមួយ ។ ដើម្បីបន្តនៅកន្លែងមួយ»។ នៅឆ្នាំ 2022 និងលើសពីនេះ តើអ្នកនឹងធ្វើការប្តេជ្ញាជាថ្មីដើម្បីគោរពតាម ការអាន និងការយល់ដឹងពីព្រះបន្ទូល ជំនឿ និងការគោរពតាមព្រះបន្ទូលរបស់ទ្រង់ដោយរបៀបណា ?

---

---

---

ព្រះបន្ទូលគឺជាគ្រឹះដ៏រឹងមាំសម្រាប់យើង។

អ្នកណាស្ដាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្តតាម
អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់
ដែលបានសាងសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម។
ម៉ាថាយ ៧:២៤

អម្ចាស់ដែលគង់នៅនគរឋានសួគ៌
អរគុណសម្រាប់ការទាំងអស់ដែលទ្រង់បានធ្វើមកកាន់ជីវិតរបស់កូននៅសប្ដាហ៍នេះ
អរគុណដែលបានព្រះភក្ដិនៅពីមុខកូននៅពេលដែលកូនស្វែងរកទ្រង់ហើយតែងតែ
ស្មោះត្រង់ចំពោះការឆ្លើយតបមកកាន់កូន។
ទ្រង់បានផ្ដល់អោយនៅអំណោយទាននៃព្រះបន្ទូលរបស់ទ្រង់
ដែលកូនអាចសាងសង់ជីវិតរបស់កូននៅលើថ្មដ៏រឹងមាំនៅក្នុងព្រះរាជ្យរបស់ទ្រង់។
សូមជួយកូនអោយភ្ជាប់ខ្លួនជាមួយនឹងព្រះបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ
ដើម្បីអោយជិតជាប់នៅក្នុងដួងចិត្តកូន
ហើយទទួលបានោបតពិសោធន៍នៃការផ្លាស់ប្រែជីវិតទាំងស្រុង
ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ដ
អាម៉ែន!